ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ✣ ៚

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៦៣៣ អយក.ប្រក

# ប្រកាស

## ស្តីពី ការប្តូរឈ្មោះសាលាបឋមសិក្សា អន្លង់ខ្មែរ មកជាសាលាបឋមសិក្សា ម៉ឺន រ៉ានី ហ៊ុន សែន អន្លង់ខ្មែរ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតស្នើសុំរបស់នាយកសាលាបឋមសិក្សា អន្លង់ខ្មែរ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត តាកែវ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

## ស ំ រ េ ច

**ប្រការ១** : ប្តូរឈ្មោះសាលាបឋមសិក្សា អន្លង់ខ្មែរ មកជា សាលាបឋមសិក្សា ម៉ឺន រ៉ានី ហ៊ុន សែន អន្លង់ខ្មែរវិញ ដែលមានទីតាំងស្ថិតនៅ ភូមិ អន្លង់ខ្មែរ ឃុំ ស្លា ស្រុក សំរោង ខេត្ត តាកែវ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក សំរោង នាយកសាលាបឋមសិក្សា ម៉ឺន រ៉ានី ហ៊ុន សែន អន្លង់ខ្មែរ មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត តាកែវ

"**<u>ដើម្បីជូនជ្រាបជាពត៌មាន</u>**"

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា.បស

ភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី